**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០២០ សហវ.ទក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១១

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ :** សំណើអន្តរាគមនីទៅភាគីកូរ៉េ ដើម្បីស្នើសុំឥណទានសម្បទានចំនួន ៤០.២៨៣.០០០ ដុល្លារអាមេរិក សម្រាប់គម្រោងអភិវឌ្ឍន៍ទំនប់ពហុបំណងស្ទឹងដូនទ្រី ។

**យោង :** លិខិតលេខ ០៣២ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមស្នើឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាអន្តរាគមនីទៅភាគីកូរ៉េក្នុងការស្នើឥណទានសម្បទានចំនួន ៤០.២៨៣.០០០ ដុល្លារអាមេរិក សម្រាប់គម្រោងអភិវឌ្ឍន៍ទំនប់ពហុបំណងស្ទឹងដូនទ្រី។ សូមគោរពភ្ជាប់ជាមួយនូវ Proposal for EDCF Loan for the Project for Dauntri Multi-purpose Dam Development ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

***ចម្លងជូន:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងធនធានទឹក និងឧតុនិយម*
- *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *ឯកសារ-កាលប្បវត្តិ*